# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧៩៤ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការវាយតម្លៃលើ ផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រ ក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង

៙ ៙ ៙

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០២ លើសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ២៧៦៣ សហវ វស ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២ ។

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីធ្វើការវាយតម្លៃលើផលប៉ះពាល់ដល់ សំណង់ ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រ ក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង ។

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ញាណ ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២. | លោក **គ្រាត់ ស៊ីផាវ៉ា** | អភិបាលរងទី ២ ក្រុងព្រះសីហនុ | សមាជិក |

៣. លោក **សេ បរម** អនុប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួយការ

៤. លោក **ខត្រ ពិសិដ្ឋ** ជានាយកគំរោង អភិវឌ្ឍន៍ទីរួមខេត្ត-ក្រុង ក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

៥. លោក **ថូ គុណនុវឌ្ឍន៍** ប្រធានការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួយការ

៦. លោក **ឌូ ចាន់នី** មន្ត្រីគំរោងការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួយការ

**ប្រការ ៣ :** គណៈកម្មការអន្តរក្រសួង មានភារកិច្ចចុះទៅពិនិត្យដល់ទីកន្លែង ធ្វើស្ថិតិលើផលប៉ះពាល់ដល់សំណង់ ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រ ក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង រួចធ្វើការវាយតំលៃឱ្យបានសមស្រប ដើម្បីមានមូលដ្ឋានដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេចនូវថវិកាមួយចំនួនជាគោលនយោបាយជូនដល់ប្រជារាស្ត្រវិញ ។

**ប្រការ ៤ :** គណៈកម្មការនេះ មានសិទ្ធិបង្កើតអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ ជាសេនាធិការផ្ទាល់ និង មានសិទ្ធិប្រើប្រាស់ការិយាល័យគោលនយោបាយ និង ផែនការ នៅនាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន សំរាប់បំពេញការងារប្រចាំថ្ងៃ ។

**ប្រការ ៥ :** ក្រសួងសាធារណការ និង ដឹកជញ្ជូន , សាលាក្រុងព្រះសីហនុ , នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ , នាយកដ្ឋានទ្រព្យរដ្ឋ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

ចំលងជូន :

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ដូចប្រការ ៥

-ឯកសារកាលប្បវត្តិ